**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
**មន្ទីរមុខងារសាធារណៈ ខេត្តក្រចេះ**
**ក្រុមលទ្ធកម្ម**
លេខ: ..០០២.... ម. ស. ក្រច ល. ក

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹងស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

គម្រោងជួសជុលអគារស្នាក់នៅ ដំណាក់កាលទី១ របស់មន្ទីរមុខងារសាធារណៈ
ខេត្តក្រចេះ សម្រាប់ឆ្នាំ ២០១៩

មន្ទីរមុខងារសាធារណៈ ខេត្តក្រចេះ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា មន្ទីរមុខងារសារធារណៈ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើស "អ្នកទទួលការ" ធ្វើការងារជួសជុលអគារស្នាក់នៅ ដំណាក់កាលទី១ របស់មន្ទីរមុខងារសាធារណៈ ខេត្តក្រចេះសម្រាប់ឆ្នាំ២០១៩។

មន្ទីរមុខងារសាធារណៈ រៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅមន្ទីរមុខងារសាធារណៈ ខេត្តក្រចេះ ដែលមានអាសយដ្ឋានភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ចាប់ពីថ្ងៃទី២៣ខែមករាឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៣១ ៣១០២០៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរមុខងារសារធារណៈ ខេត្តក្រចេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ០៨:០០។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅមន្ទីរមុខងារសាធារណៈ ខេត្តក្រចេះ តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៨:០០ ថ្ងៃទី ២៣.. ខែ ឧសភា.. ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មនៃមន្ទីររបស់មន្ទីរមុខងារសារធារណៈ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃសុក្រ ១០រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅក្រចេះ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩
**ប្រធានមន្ទីរ និង ជាប្រធានក្រុមលទ្ធកម្ម**

រស់_ជាទុង

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ "កាលប្បវត្តិ"